តើអ្នកជឿលើរឿងអបិយជំនឿ មន្តអាគម ខ្មោចព្រាយបិសាចដែររឺទេ?បើជឿ តើជឿកម្រិតណាដែរ? ចុះអ្នកធ្លាប់ដឹងអ្វីខ្លះទាក់ទងនិងរឿងអស់នេះ? នៅក្នុងរឿង គំនូស៤៩កាលពីលើកមុនយើងបានដឹងពីលើរឿងពិតមួយរបស់ស៊ាំង គឺមស្រ្ត។ ចំណែកពេលនេះ ខ្ញុំមានរឿងពិតមួយរបស់អ្នកស្រីចន្ថាមកចែករំលែក។

---

...ព្រលប់ហើយ....មេឃស្លុបតាំងពីម៉ោងបីរសៀល....ផ្គរលាន់តិចតួចមកពីគ្រប់ទិស...ប៉ុន្តែអត់ភ្លៀងរួចសោះ....ផ្គរបានត្រឹមតែគ្រហឹមគ្រឹមៗ....យូរៗម្តងៗ។

នៅក្នុងភូមិគ្រឹះលោក វិសេសជាមេធាវីដ៏ល្បីឈ្មោះបែរជាលេចចេញនូវសូរសម្លេងឈ្មោះប្រកែកគ្នាទៅវិញ។

«អូនឯងគិតយ៉ាងម៉េចចន្ថា?នេះគេមកសួរកូនជិត៣០នាក់ហើយមិនព្រមលើកអោយគេ?!»

ភរិយានៅស្ងៀម ធ្វើអោយប្តីកាន់តែសង្ខើញះ

«កូនវីនអាយុជាងម្ភៃហើយ!មុខមាត់ប៉ុណ្ណឹងដែរ ចង់អោយកូនស្រីនៅក្រមុំសៅកែ?»

ដាវីនដែលឈរលបស្តាប់នៅក្រៅបន្ទប់ធ្វើមុខស្ងួត។នាងក៏គិតមិនយល់ពីមូលហេតុនៅពីក្រោយភាពតឹងតែងរឿងគូរស្រករក្នុងចិត្តអ្នកម្តាយដែរ។ព្រោះតាំងពីតូចក្រូចឆ្មារមកនាងជាកូនស្រីតែមួយរបស់លោកមេធាវី ហើយមានទ្រព្យសម្បត្តិស្តុកស្តម្ភថែមទាំងមិនដែលហ៊ានប្រព្រឹត្តិអ្វីឆ្គាំឆ្គងអោយឪពុកម្តាយពិបាកចិត្តទេ ចុះ ហេតុអ្វីដល់វ័យ២៥ឆ្នាំហើយម្តាយនៅតែបដិសេធរាល់បុរសដែលចូលមកស្តីដណ្តឹង?។រឺមួយលោកគិតថា បុរសទាំងនោះមិនល្អខ្លាចនាំទុក្ខដល់អនាគតកូនស្រីតែមួយរបស់គាត់?

សូរសម្លេងលោកពុកនាងលាន់មកបន្ថែមះ

«កូនប្រុសលោកបងសម្បត្តិគឺគេជានិស្សិតឆ្នើមមកពីក្រៅភ្លាមមានតួនាទីក្នុងរដ្ឋាភិបាលភ្លែត។ រូបរាងកម្ពស់កំពក៏បាន ចរិតមារយាទល្អ គេស្រលាញ់កូនយើងតាំងពីនៅតូចៗមក!ឥឡូវគេត្រឡប់មកវិញភ្លាមចូលសួរភ្លាមទុកមុខមាត់អោយប៉ុណ្ណឹង អូនឯងចេះមកបដិសេធគេទទឹងទិសរកតែបងនិយាយអីក៏មិនទាន់ ក្រៅពីគេអន់ចិត្ត គឺកូនវីនក៏គ្នាខូចចិត្ត។ក្មេងៗស្រលាញ់គ្នា មានអីត្រូវគិតទៀត គេចូលដល់ផ្ទះទៅហើយទៅជំទាស់គេ ឥឡូវអូនឯងចង់រង់ចាំកូនប្រ សារមកពីឋានសួគ៌ណាទៅបានអូនឯងត្រូវចិត្តចន្ថា?»

ដាវីនឈ្ងោកមុខស្រពាប់ស្រពោនព្រោះសម្តីពុកមានន័យថាដែលខាងប្រុសខំលើកជំនួនមកសួរកាលពីព្រឹកគឺត្រូវម្តាយជំទាស់បាត់ទៅហើយ អោយនាងសង្ឃឹមអីទៀតបើគាត់បដិសេធគេរួចទៅហើយ។ គេមានមុខមាត់ គ្រួសារគេមានគេឯងស្គាល់ច្រើន កូនកំលោះគេប៉ុណ្ណឹងៗដែរ គេមានរឿងអីថាមិនអន់ចិត្ត?។ដាវីពិបាកចិត្តណាស់ នាងបែរក្រោយយឺតៗត្រឡប់ទៅអង្គុយក្នុងបន្ទប់ខ្លួនវិញ ប៉ុន្តែលឺម្តាយនិយាយរអាក់រអួលតិចៗ៖

«ខ្ញុំឯណាមិនចង់បានកូនប្រសា រល្អដូចកូនល្បងសម្បត្តិ?ប៉ុន្តែ....ប៉ុន្តែខ្ញុំមានការលំបាកនិយាយមិនចេញមែន!»

ថាចប់អ្នកស្រីក៏យំហ៊ូធ្វើអាយដាវីននឹកអាណិតម្តាយភ្លាម។នាងបញ្ឈប់ដំណើរសឹងតែថាស្ទុះចូលទៅអោបគាត់ហើយលួងលោមគាត់ថា ម៉ាក់អើយកូនមិនត្រូវការទេ កូននៅជាមួយម៉ាក់រហូតក៏បានកុំ អោយតែម៉ាក់ពិបាកចិត្ត។មិនទាន់អីផងលោកមេធាវីប្តូរសូរសម្លេងសួរភរិយាតិចៗវិញ៖

«ការលំបាក អី និយាយចេញមក!»

ស្ត្រីអភិជននៅរក្សាការស្ងប់ស្ងាត់ជាមួយដំណក់ ទឹកភ្នែក។ប្តីឃើញដូច្នោះក៏និយាយបន្ថែម៖

«គ្មានការលំបាកអីដោះស្រាយមិនចេញទេអូន!ធ្វើជាឪពុកម្តាយគេ សំខាន់បំផុតគឺសុភមង្គលរបស់កូន!ដើម្បី កូន ការលំបាកអីក៏ត្រូវស្រាយអោយចេញដែរ!ល្ងាចនេះបងនឹងទៅរកលោកបងសម្បត្តិដល់ផ្ទះ សុំទោស គេ ហើយធ្វើមុខក្រាសនិយាយប្រាប់គេថា យើងព្រមរឿងក្មេងៗហើយ ចំណែកពាក្យអូនឯងបដិសេធពីព្រឹកមិញ ចាំបងប្រាប់ថាមកពីអារម្មណ៍អូនឯងមិនសូវល្អ!បានហើយ!ស្អីៗទុកអោយបងដោះស្រាយ!គេខាងណោះក៏គេមិនពិបាកនិយាយគ្នាដែរ ម្នាក់ៗសុទ្ធតែទុកសុភមង្គលក្មេងៗជារឿងសំខាន់ទាំងអស់»។

លោកមេធាវីឈានជើងចេញទៅ តែត្រូវភរិយាឃាត់ពីក្រោយខ្នងភ្លាម៖

«រៀបការបាន!ប៉ុន្តែ....ប៉ុន្តែមិន អោយធ្វើជប់លៀងភ្ញៀវទេ...រៀបការតូចតាចធម្មតាជាលក្ខណៈគ្រួសារទៅ!»

ដល់វេនដាវីនឆ្ងល់ម្តង។ម៉េចក៏អ្នកម្តាយខ្លួនមានលក្ខខណ្ឌដ៏ចម្លែកនេះ?ពិធីមង្គលការជារឿងដ៏សំខាន់បំផុតក្នុងជីវិតមនុស្សម្នាក់ៗ ទោះបីជាកម្មវិធីសំពះ ផ្ទឹម សែនចងដៃពេលព្រឹកតាមប្រពៃណីពិតជាសំខាន់មែនប៉ុន្តែលៀងអាហារពេលល្ងាចក៏សំខាន់ដែរក្នុងសង្គម ស៊ីវិល័យបច្ចុប្បន្នហេតុអ្វីគាត់បែរជាចង់កាត់ពិធីដ៏មហោឡារិកនោះចោល។នាងត្រដុសដៃទាំងសងចូលគ្នាទាំងតឹងចិត្តនិងអាកប្បកិរិយាដ៏ចម្លែករបស់ម្តាយ។នាងមិនខឹងគាត់ទេប៉ុន្តែកាន់តែលបស្តាប់ក្នុងចិត្តនាងកាន់តែនឹកឆ្ងល់ជាខ្លាំងថា

អ្វីៗទៅដែលធ្វើអោយអ្នកម្តាយប្រកបដោយព្រហ្ម វិហារធម៌របស់ខ្លួនបែរជាមានសំណូមពរដ៏ចម្លែកនេះ។

នាងនៅភាន់ភាំង ឯឪពុកកើតឆេះដុំ៖

«ស្អីគេ?អ្ហះ?ស្តាប់ច្រឡំទេអ្វី?កូនស្រីតែមួយ មកការរៀបគ្រួសារ?អត់ជប់លៀងពេលល្ងាច?អ្ហះចន្លា?ឱបមាថាខ្ញុំព្រមតាមអាគំនិតឡប់ៗនេះ ចុះខាងប្រុស គិតថាគេព្រមដែរ?អាសំណូមពរឡប់ៗនេះ!»

លោកមេធាវីនិយាយហើយចាកចេញទាំងខឹង ណែនទ្រូងតែត្រូវភរិយាឈោងមកចាប់ដៃជាប់។

«បង!ស្តាប់អូនសិន!អូនមិនចង់ទេ....តែអូនធ្វើនេះដើម្បីកូនវីន!បងឃើញហើយ ស្រីៗក្នុងគ្រួសារយើង អោយតែអ្នកណាហ៊ានរៀបការ នៅយប់ជប់លៀងសុទ្ធតែជួបគ្រោះថ្នាក់ដល់ជីវិត!អូនខ្លាចណាស់ អូនខ្លាចណាស់បងវិសេស!យល់ចិត្តអូនផង!»

ដាវីនបើកភ្នែកធំៗស្ទើរមិន ជឿត្រចៀកខ្លួនឯង។នេះរឺ មូលហេតុដែលម្តាយនាងតែងបដិសេធរាល់ការស្តីដណ្តឹងកូនស្រី?នាងនៅទ្រឹងភាន់ភាំង ឯលោកជាឪពុកគំហកដាក់ភរិយា៖

«និយាយពាក្យអពមង្គលឆ្កួត យក៍អីហ្នឹងចន្លា?»

ស្ត្រីភរិយាមេធាវីល្បីយំលើសដើម គាត់ក្រោកជិត ស្វាមីដែលពេញដោយទឹកមុខកំហឹងនិងមិនទទួលស្គាល់សម្តីគាត់។តែក្នុងនាមភរិយាគាត់ខំនិយាយពន្យល់ទៀតទាំងអណ្តឺតអណ្តក៖

«បងនៅចាំរឿងសក្ក ណាប្អូនស្រីបងអត់?»

មេធាវីវិសេសធ្វើភ្នែកក្រឡិកក្រលាប់ព្រោះរឿងហេតុកន្លងទៅជាង១០ឆ្នាំហើយ បើកុំភរិយារំលឹកលោកនឹកមិនឃើញទេថាប្អូនស្រីនោះស្លាប់ក្នុងថ្ងៃមង្គលការគឺចំពេលាជប់លៀងទទួលភ្ញៀវមុនពេលផ្សំដំណេក។

«អូនឯងចង់និយាយស្អីរឿងសក្ក ណាហ្នឹង?រឿងមនុស្សស្លាប់យូរហើយយកមកនិយាយធ្វើអី?»

អ្នកស្រីចន្លាតបវិញរឹង៖

«តែសក្កណាស្លាប់ក្នុងយប់រៀបការគឺពេលជប់លៀងទទួល ភ្ញៀវ.....»

ស្វាមីនិយាយកាត់ រឹង៖

«ដោយសារអញ្ចឹងអូនឯងមិនចង់អោយកូនស្រីជប់លៀងរៀបការទេ?សក្ក ណាស្លាប់ជារឿងគ្រោះថ្នាក់របស់សក្កណា ហើយវាកន្លងទៅយូរណាស់ហើយ ចំណែកកូនវីនរៀបការមានអីទាក់ទងគ្នាទៅ?»

«តែអូនភ័យ....អូនមានកូនស្រីតែមួយ បើមានរឿង អីកើតឡើងចំពោះកូនវីន អូនស្លាប់ល្អជាង!សក្កណាស្លាប់បងថាមកពីនាងមានគ្រោះថ្នាក់ ចុះក្មួយស្រីបង ក្មួយពេជ្រកាលពី៦ខែមុនរៀបការនៅអាមេរិកម៉េចក៏ស្លាប់ក្នុងយប់ជប់លៀងដែរ?ហើយនៅចាំអត់ ប្អូនស្រីជីដូនមួយបងឯង ក៏ធ្លាប់ស្លាប់ក្នុងយប់រៀបការដែរអានេះបងឯងអ្នកប្រាប់ខ្ញុំផ្ទាល់ សរុបមកវិញខ្ញុំយល់ថាស្រីៗក្នុងផ្ទះនេះ គឺមានបញ្ហាក្នុងយប់រៀបការជួន គ្នារ៉េះ?រឿងនេះនៅតែតាមលងអារម្មណ៍ខ្ញុំ! ខ្ញុំភ័យ គឺខ្ញុំភ័យ មែន»។

លោកមេធាវីហួសចិត្តចំពោះការវិភាគគ្មានមូលដ្ឋានរបស់លោកស្រីគាត់ដកដង្ហើម ធំៗនេះបើកុំតែថារឿងហេតុកើតក្នុងគ្រួសារខ្លួនឯងផ្ទាល់កុំអីលោកមិនបានចំណាយពេលវេលាមកស្តាប់ការវិភាគអគតិអស់នេះហើយចំណាយពេលពន្យល់នោះទេ។ឃើញភរិយាកាន់តែធ្លាក់ក្នុងអន្លង់ ទុក្ខដ៏តឹងតែងគាត់បន្ធូរឥរិយាបថបកក្រោយមកអង្អុយទន្ទឹមលោកស្រីហើយស្ដីតិចៗពន្យល់៖

«ចន្ថា!គេមិនដែលយករឿងមកបូកគ្នាអញ្ចឹងទេ!នេះជាសម័យវិទ្យាសាស្រ្ត!ឈប់ដេកភ័យដេកគិតដេកស្លុតជាមួយរឿងគ្មានបានការអស់នេះចន្ថា!គ្មានទេអារឿងអពមង្គលនេះកើតឡើងទៀតក្នុងផ្ទះយើង!រឿងហួសហើយយកវាមកបន្លាចខ្លួនឯងឃើញអត់?វាបានអីមកវិញ?បានត្រឹមតែធ្វើអាយខ្លួនឯងភ័យស្លន់វង្វេងវង្វាន់ធ្វើបាបអនាគតកូនស្រីខ្លួនឯង!ត្រជាក់ចិត្តទៅ!ចាំបងទៅនិយាយជាមួយខាងលោកបងសម្បត្តិអោយគេអញ្ជើញអាចារ្យពូកែៗរកពេលាល្អបំផុតមួយអោយកូនស្រីយើង!»

អ្នកស្រីនៅស្ងៀមទាំងតឹងចិត្ត។គាត់មិនមែនមិន ចង់បានកូនប្រសាទេ ចំណែកកាលដែលព្រឹកមិញដាច់ចិត្តបដិសេធសំណើរបស់គ្រួសារលោកសម្បត្តិគឺជាការសម្រេចចិត្តដ៏លំបាក មួយព្រោះគាត់ក៏ស្តាយកូនប្រុសដ៏ពូកែនោះណាស់ ប៉ុន្តែទោះយ៉ាងណាអាយុជីវិតកូនស្រីនៅតែជារឿងអាទិភាព។ឃើញអ្នកស្រីនៅស្ងៀម លោកមេធាវីបន្ត៖

«អនាគតកូនសំខាន់ជាងអីទាំងអស់!បងមិនខ្វល់រឿងអីទេ!អស់លុយប៉ុន្មាន ធ្វើយ៉ាងណាក៏ដោយ គេលើកជំនូនដល់ផ្ទះ ហើយកូនប្រុសគេល្អកម្ររក ត្រូវធ្វើមុខ ក្រាសទៅសុំទោសគេក៏បងត្រូវធ្វើ សុំតែអូនឯងនៅទីនេះឈប់គិតរឿងអាក្រក់ៗបន្លាចខ្លួនឯងទៀត!រឿងកន្លងហួសហើយ គឺវាហួសហើយ! យើង វិញមួយជាតិនេះធ្វើតែអំពើល្អ គ្មានរឿងអាក្រក់អីមកកើតលើយើងរួចទេ!»

គាត់ចាកចេញ ទៅទុកភរិយានៅជូតទឹកភ្នែកព្រោះធូរទ្រូងបន្តិចដោយទទួលបានការពន្យល់លួង លោមពីប្តី។ឃើញគាត់រាងធូរស្រាលពីទុក្ខកង្វល់ ដារីនជាកូនក៏ដើរមួយៗមករកម្តាយ។ឃើញកូនស្រី ភ្លាម លោកស្រីមេធាវីទៅជាភាន់ភាំង ។

«កូនស្តាប់លឺអស់ហើយដារីន?»

ដារីមិនឆ្លើយតែនាងជ្រប់មុខជាសញ្ញាទទួលថាដូចអ្នកម្តាយនិយាយ ពិតមែន។ឃើញដូច្នេះលោកស្រី ចាប់ពន្យល់នាង៖

«កូនស្រី!កុំខឹងម៉ាក់ណ៎ា!ម៉ាក់គិតពីកូនម៉ាក់បារម្ភពីកូនតែប៉ុណ្ណោះ!តែពេលនេះម៉ាក់ឈប់គិតហើយ! ប៉ាឯងនិយាយត្រូវ មនុស្សយើងសាងតែអំពើល្អ យើងគ្មានរឿង អ្វីត្រូវជួបអំពើអាក្រក់ទេ!សង្ឃឹមថា លើកនេះគ្រួសារលោកបងសម្បត្តិគេអត់ប្រកាន់ ម៉ាក់ចង់អោយកូនម៉ាក់ ក្លាយជាកូនប្រសាផ្ទះនោះ ព្រោះគេជាអ្នក ល្អរាប់អានគ្នាយូរមកហើយ កូនប្រុសគេនោះល្អមិនងាយរកទេទាំងរូបសម្បត្តិ វិជ្ជា សម្បត្តិណ៎ាកូន ហើយពួក កូនស្រលាញ់រាប់គ្នាតាំងពីតូចៗមកផង!»

នារីអភិជនមិននិយាយស្តីតែនាងលោមកអោបម្តាយពេញក្នុងរង្វង់ដៃជាសញ្ញាដឹងគុណចំពោះព្រហ្ម វិហារធម៌របស់លោក។

ដោយគ្រួសារខាង ប្រុសមានការយោគយល់នឹងពិតជាចង់ ផ្សារសាច់ឈាមគ្រួសារទាំងពីរមែន ដូច្នេះ មង្គលការកញ្ញាដារីនកូនស្រីទោលរបស់មេធាវីវិសេសនិងមន្រ្តីរាជការវ័យក្មេង សម្បូរកូនលោក សម្បត្តិត្រូវបានរៀបចំឡើងដោយពង្រាងម៉ត់ចត់តាមរបៀបអ្នក ថ្កុំថ្កើងខាងហិរញ្ញវត្ថុ។

លោកស្រីភរិយា មេធាវី ល្បី ឈ្មោះ ហេតុតែ ពេញចិត្តពេញ ថ្លើម ចំពោះ អនាគត កូនប្រសា រ ប្រុស បានបង្ខំចិត្តលុបចោលសេចក្តីមន្ទិលដែលខ្លួនបានលាក់ចប់ក្នុងផែន ទ្រូងជាច្រើនឆ្នាំមកហើយនោះ ពោលគឺបានចាត់ចែងអាចារ្យគន់គូរមើលថ្ងៃជាពេលាល្អដើម្បីធ្វើពិធីភ្ជាប់ ពាក្យយ៉ាងអធឹក អធម៌អ្នក មុខអ្នកការជាច្រើនបាន នាំគ្នាមកចូលរួមហើយជញ្ជក់មាត់សរសើរភាពសក្តិសមគ្នានៃកូនកំលោះក្រមុំ ទាំងទ្វេធ្វើអោយឪពុកម្តាយទាំងសងខាងញញឹមបិទមាត់មិនជិត។

រហូតដល់ល្ងាចសម្រាកពីការទទួលភ្ញៀវ ដោយក្នុងផ្ទះសល់តែគ្រួសារទាំងសងខាងលោកមេធាវីនិង លោកស្រី ក៏អញ្ជើញអាចារ្យគន់គូររកមើលពេលារៀបការនៅចំពោះមុខដន្លងផង។បន្ទាប់ពីវាយលេខ អត្តរួចរាល់ហើយលោកអាចារ្យបានកំណត់យកថ្ងៃទី២៩ខែក្រោយជាថ្ងៃចូលរោងការ។ញាតិទាំង សងខាងបានស្រុះស្រួលលៃលកយកតាមថ្ងៃជាពេលាល្អនេះហើយទើបបំបែកគ្នាទៅចាត់ចែងតាមភា រៈរៀងៗខ្លួនព្រោះពេលវេលាជាងមួយខែគឺខើចហួសសម្រាប់ការរៀបចំមង្គលការកូនស្រីតែមួយគត់

របស់លោកមេធាវី។ដោយសារតែចង់អោយវៀរចាកឧបទ្រពចង្រៃទាំងអំបាលម៉ានទេទើបឪពុកម្តាយនាងសុខចិត្តធ្វើតាមពេលានេះដោយតក់ក្រហល់។

អ្នកស្រីចន្ថាជាម្តាយនាងដាវីនបានលើកយកសន្លឹកប្រក្រតិទិនដែលអាចារ្យបានគូរ រង្វង់ចំណាំលើលេខម្តៃប្រាំបួននោះយកទៅអោយកូនស្រីរក្សាទុក។ប៉ុន្តែបរិយាកាសសប្បាយរីករាយមិនទាន់ដំណើរការទៅបានប៉ុន្មានម៉ោងផង ស្រាប់តែធីតាតែមួយគត់នៃត្រកូលមេធាវីបានរត់រលះរលាំងមករកម្តាយដែលកំពុងអង្គុយចិតផ្លែឈើនៅមុខទូរទស្សន៍។នាងធ្វើមុខងឿងឆ្ងល់ ហើយសាកសួរម្តាយទាំងមានកាន់ប្រក្រតិទិនក្នុងដៃ៖

«អ្នក ម៉ាក់!ល្ងាចមិញនេះលោកអាចារ្យគន់គូរយកថ្ងៃ២៩មេនទេអ្នកម៉ាក?»

ស្ត្រីនោះងឿងឆ្ងល់ចំណោះអាកប្បកិរិយារលះរលាំងរបស់កូនស្រី គាត់មានអារម្មណ៍មិនសូវល្អទេពេលឃើញនាងមកជាមួយប្រក្រតិទិនក្នុងដៃប៉ុន្តែគាត់ខំទប់ចិត្តសួរវិញតាមសម្រួលថា៖

«ម៉េចហ្នឹងកូនវីន?ថ្ងៃ២៩ខែក្រោយមែនតើ ?មានរឿងអីកូន?»

«ប៉ុន្តែអ្នក ម៉ាក់មើលចុះ កលើនេះគាត់គូសថ្ងៃទី៣១សខែក្រោយសោះហ្នឹង?»

ស្ត្រី ដូរទឹកមុខព្រោះមិនជឿសម្តីកូនស្រីហើយគាត់ដៀងភ្នែកក្រឡេកទៅមើលស្នាមគំនូសជារង្វង់លើសន្លឹកប្រក្រតិទិនដែលកំពុងលាបង្ហាញមកចំពោះមុខ។រង្វង់ពិតជាគូសចំថ្ងៃទី៣១មែន ចុះម៉េចក៏ល្ងាចមិញអាចារ្យប្រាប់អ្នករាល់គ្នាថា ថ្ងៃ២៩?តើគាត់និយាយខុស គូសត្រូវ រឺនិយាយត្រូវតែគូសខុស?

ស្នូររថយន្តនៅខាងក្រៅលាន់ជ្រែកភាពស្ងប់ស្ងាត់នៃរាត្រីកាលបង្ខំអោយស្ត្រីដាក់សន្លឹកនោះចុះពីដៃហើយក្រោកទៅទទួលដំណើរស្វាមីដូចសព្វមួយដង។កូនស្រីបានទៅចូលចាត់ចែងជាមួយអ្នកបម្រើរៀបអាហារពេលយប់ ចំណែកស្ត្រីឈ្មោះចន្ថាទៅទទួលអាវធំនិងកាបូបពីស្វាមីដល់មាត់ទ្វារជាមួយទឹកមុខខ្វាយខ្វល់។គាត់ឃើញស្វាមីញញឹមញញែមជាសញ្ញា ថាការប្រសប់នៃ គម្រោងមង្គលការកំពុងធ្វើអាយលោកមេធាវីស្រស់ស្រាយមិនទាន់បាត់នៅឡើយ។គាត់នៅ មិនសូវសប្បាយចិត្តនឹងរឿងផ្ទុយគ្នារវាងថ្ងៃដែលអាចារ្យប្រាប់និងគំនូសក្នុងរង្វង់ប្រក្រតិទិនប៉ុន្តែនៅមិនទាន់ហ៊ាននិយាយអ្វីទេ នេះ ជាទម្លាប់ស្ត្រី ខ្មែរដែលតែងតែព្យាយាមលាក់បាំងរឿងមិនស្រួលចិត្តនៅ ពេលប្តីទើបតែមកដល់ផ្ទះ។

«តោះ!អូនទៅលាយទឹកក្តៅអោយត្រាំខ្លួន»

បុរសមេធាវីដូចជានៅសប្បាយចិត្តពីរឿងមង្គលរបស់កូនស្រីតែម្នាក់គត់ដែលហៀបនឹងចូលមកដល់ ។គាត់ងាកមកញញឹមដាក់ភរិយាហើយវាចាប្រាប់៖

«បងនិយាយជាមួយគេរួចហើយ មង្គលការកូនវីននឹងចាត់ចែងជាពិធីGrandតែម្តង!តែខាងយើងអត់ហត់អីទាំងអស់ ក្រុមហ៊ុននោះគេមានកំប្លេ យើងត្រៀមតែខ្លួនទៅទេ!»

ស្វាមីនិយាយផងអង្គុយទៅលើសាឡុងលើកយកផ្លែផ្កាដែលភរិយាទើបចិតរួចនោះមកទំពាគ្រួបៗ បែបមានសេចក្តីសុខផង។ស្ត្រីជាភរិយាឃើញដូច្នេះគាត់បញ្ឈប់ដំណើរដែលបម្រុងយកអាវទៅព្យួរទុកបែរជាងាកមកសួរប្តីពីក្រោយខ្នង៖

«បងអ្ហា»ព្រឹកមិញលោកតាអាចារ្យគន់គូរចំថ្ងៃ២៩មែនអត់បង?»

«ហ្នឹងហើយ!ចំថ្ងៃចន្ទ័ ដើមទ្រព្យតែម្តង!»

ពេលស្វាមីនិយាយធ្វើហី ស្ត្រីកាន់តែពិភាល់ក្នុងចិត្ត។អ្នកស្រីចន្ថាងាក ទៅរកបុត្រីដែលកំពុងរៀបចំចានក្បានលើតុបាយវែងជាមួយអ្នកបម្រើ ម្តងៗកុលធីតាងាកមកមើលមុខម្តាយនិងបញ្ចេញភាពស្រងូតតាមពន្លឺភ្នែកដែរ។

ស្ត្រីអភិជនមិចភ្នែកជាសញ្ញាថាកុំអោយកូននិយាយអីចាំអោយប៉ាពិសា របាយបានរួចរាល់សិន។

រាត្រីកាលចូលមកដល់ ស្វាមីដែលនឿយហត់ពីកិច្ចការនានាបានសម្រាកលក់ ស្កប់ស្កល់ ប៉ុន្តែអ្នកស្រីចន្ថានៅតែមិនស្រួលក្នុងចិត្តសោះ។អ្វីដែលគាត់នឹកមិនសុខមិនសាប់នោះគឺតើកូនស្រីបានពេលាថ្ងៃទី២៩រឺក៏ថ្ងៃទី៣១?

ចំណោទបញ្ហាបណ្តាលអោយអ្នកស្រីលង់លក់ទាំងលេខ២៩និង៣១តាមលងរហូតដល់ក្នុងសុបិន្តធ្វើអោយគាត់រងនូវសុបិនចម្លែកជាច្រើនជួបមនុស្សប្លែកៗមុខនៅកន្លែងគួរអោយខ្លាចហើយពិសេសគឺមិនដឹងថាទីណាជាទីណាអ្នកណាជាអ្នកណាសោះ។ទីបំផុតនៅម៉ោង៤ទៀបភ្លឺគាត់តក់ស្លុតស្រែកភ្លាត់សូរសម្លេងទាំងក្នុងដំណេកដាស់ស្វាមីដែលគេងក្បែរអោយភ្ញាក់ដូចគេកន្ត្រាក់ហើយលោកមេធាវីងាកមកដាស់អង្រួនភរិយាដែលភ័យស្លុតញ័រខ្លួនព្រោះសុបិនអាក្រក់ពេលទៀបភ្លឺ។

«កើត អី?ចន្ថា?កើត អី?យល់សប្តអាក្រក់?»

អ្នកស្រីស្ទុះ ក្រោកអង្គុយទាំងហត់គយូសបែកញើសជោគ ខ្លួន។

«បង!ខ្ញុំយល់សប្តិអាក្រក់! ខ្ញុំយល់សប្តិអាក្រក់!»

ស្វាមីដកដង្ហើមធំពន្យល់៖

«ដកដង្ហើមអោយវែងៗ!បំភ្លេចចោលអោយអស់ ទៅ!»

«អត់ទេ បំភ្លេចអត់បានទេ!ឯណា ?ឯណាកូន?ខ្ញុំទៅរកកូនខ្ញុំសិន!»

អ្នកស្រីស្ទុះ ងើបរឹងចេញទៅកាន់បន្ទប់បុត្រីដែលនៅក្បែរនោះហើយគោះទ្វារញាប់ រន្ទើនរហូតដល់ដាវីនភ្ញាក់ ដឹងខ្លួនទាំងមុខភ័យព្រួចស្លេកស្លាំងមកបើកទ្វារអោយម្ដាយ។ឃើញកូនកាលណាអ្នកស្រីចន្ទាស្ទុះ រឹងអោបកូនស្រីផ្ទប់ដើមទ្រូង៖

«កូនវីន!កូនវីនរបស់ម៉ាក់»

គាត់យំគគ្រូក ធ្វើអោយធីតាអស់ពីភាន់ភាំងទៅជាចង់យំតាមម្ដាយតែម្ដង។បន្ទាប់ពីនោះអ្នកស្រីបានប្រាប់អ្នកក្នុងផ្ទះថា តាមពិតដែលអ្នកស្រីយល់សុបិន្តរហូតដល់ស្រែកទាល់តែភ្ញាក់គេងឯងនោះគឺ យល់សប្តិថាឃើញកូនស្រីរៀបការចំថ្ងៃទី៣១ហើយឃើញមានមនុស្សរូបចម្លែកសម្បុរ ខ្មៅរាងកាយធំៗមកវាយដំអូសនាំនាងចេញទៅ អ្នកស្រីខំឃាត់យ៉ាងណាស្រែកទួញយ៉ាងណាគេនៅតែមិន ប្រណី។អ្នកស្រីបានចាត់ទុកថានេះជាប្រផ្នូលមិនល្អទាល់តែសោះដែលធ្វើអោយថ្ងៃបន្ទាប់ឡើងអ្នកស្រីកាន់តែមិនសប្បាយចិត្តហើយធ្លាក់ខ្លួនឈឺគេងស្ដឹកលើគ្រែ។មុនពេលចេញទៅធ្វើការដូចសព្វមួយដង លោកមេធាវីវិសេសបានចូលមកក្បែរភរិយាហើយពន្យល់អោយកាត់ចិត្តកុំអោយខ្វល់គិតពីសុបិននោះអោយសោះប៉ុន្តែអ្នកស្រីបែរជាពន្យល់វិញ។

«បង!ហេតុអ្វីនៅសុខៗ អាចារ្យថាការកូនយើងថ្ងៃ២៩ទេ តែបែរជាគួរ រង្វង់លើថ្ងៃទី៣១វិញ?ហេតុអ្វីខ្ញុំក៏យល់សប្តិឃើញថាកូនយើងការចំថ្ងៃទី៣១ ហើយមានរឿងអាក្រក់ៗកើតឡើងចំពោះកូនវីន?អូនមិនស្រណុកចិត្តសោះបង! »

«មកពីអូនឯងគិតពីរឿងថ្ងៃ៣១នោះពេកបានជារហូតដល់យល់សប្តិឃើញ!ចំណែករឿងរង្វង់នោះប្រហែលអាចារ្យគាត់គូសច្រឡំក៏ថាបាន!សម្រាកទៅ»

ថារួចបុរសជាមេគ្រួសារងើបចេញចោលភរិយាព្រោះមានការងារជាច្រើននៅរង់ចាំពិសេសគាត់ត្រូវដោះស្រាយអោយហើយមុនមង្គលការកូនស្រីចូលមកដល់។ដឹងអីមកដល់ខាងក្រៅផ្ទះឃើញកូនស្រីតែមួយគត់របស់ខ្លួនឈររង់ចាំនៅមាត់ទ្វារជាស្រេច។គ្រាន់តែឃើញទឹកមុខនាងក៏ដឹងថានាងកំពុងព្រួយបារម្ភជាខ្លាំងដែរ។បុរសជាឪពុកលើកដៃអង្អែលក្បាលកូនហើយលួងលោម៖

«ឱស្សាហ៍ជជែកលួងលោមម៉ាក់ផងកូន!ម៉ាក់គិតច្រើនពេក!វាមិនអីទេ!កូនឯងកុំគិតតាមម៉ាក់ឯងណា ត្រៀមខ្លួនជិតចូលរោងការហើយ»

គាត់រួសរាន់ចេញទៅដូច រាល់ដងតែម្តងនេះគាត់ត្រូវឈប់វិញដោយសារងឿងឆ្ងល់ព្រោះថាកូនស្រី ដែលកន្លងមកមិនសូវមាត់កបានហៅគាត់តិចៗថា«ប៉ា!»។

ពេល គាត់បែរក្រោយកាលណា ដារីនរត់មកក្បែរឪពុកហើយនិយាយឡើងថា៖

«លោកប៉ា!យប់មិញក៏កូនយល់សប្តិអត់ ល្អដែរ!តែកូនមិនហ៊ាននិយាយព្រោះម៉ាក់កំពុងពិបាកចិត្ត ស្រាប់!ពេលនេះកូនជម្រាប ប៉ាព្រោះ....ព្រោះ...កូនក៏មិនសូវស្រួលក្នុងចិត្តដែរ»

លោកមេធាវីប្រញាប់ប៉ុន្តែលោកខំអត់ធ្មត់៖

«និយាយទៅកូន!យល់សប្តិថាម៉េចខ្លះ?»

បានឱកាសដារីនិយាយប្រាប់ឪពុកជាបន្ទាន់៖

«ចាសប៉ាមុនពេលដែលម៉ាក់មកគោះទ្វារកូនកំពុងយល់សប្តិអាក្រក់ណាស់ គឺយល់សប្តិថាមានស្រី ក្មេងម្នាក់វ័យប៉ុនកូនមកឈរនៅចុង គ្រែហើយចង្អុលមុខកូនរបៀបខឹងសម្បារ!មុខមាត់កាចណាស់ ហើយបើកភ្នែកធំៗសម្លក់កូនថ្មែអត់និយាយអីទាំងអស់!ពេលកូនខំប្រឹងក្រោកក៏ក្រោកមិនរួច ដៃជើង ជាប់គាំងដូច មានពីណាសង្កត់អញ្ចឹង!បន្ទាប់មកស្រីនោះស្រែកគំរាមកូនថា ដារីនៗ ដល់ថ្ងៃ៣១ជាថ្ងៃ អន្សារបស់នាងហយដារីន!បើកុំតែម៉ាក់គោះទ្វារកូនមិនងាយភ្ញាក់ពីសប្តិអាក្រក់នោះ ទេមើលទៅ!»

ឪពុកដកដង្ហើមធំព្រោះឃើញកូនស្រីកាន់តែនិយាយកាន់តែភ័យស្លេកអស់ផ្ទៃមុខ។គាត់អង្អែលក្បាល ហើយនិយាយលួងលោមភ្លាមថា៖

«ចូល ផ្ទះវិញ ទៅកូន!ចាំថ្ងៃ ប៉ាមកបាយផ្ទះ!កុំគិតច្រើនពេក យល់សប្តិនៅតែជាយល់សប្តិ វាមិនអាច ក្លាយជាការពិតបានទេ!ម្យ៉ាងពេលាកូនឯងថ្ងៃទី២៩ទេតើមិនមែនថ្ងៃទី៣១ទេ!»

កូនស្រីញញឹមទាំងក្រៀមក្រំលួងលោមចិត្តឪពុកវិញ។មេធាវីចេញមកធ្វើការពិតមែនប៉ុន្តែអារម្មណ៍នៅ តែ នឹងប្រពន្ធកូនឯផ្ទះ។ទោះបីលោកមិន ចេះជឿរឿងអប្បិយជំនឿប៉ុន្តែរឿងរ៉ាវកើតឡើងផ្ទួនៗគ្នាធ្វើ អាយលោកអង្គុយធ្វើការមិននឹងនចិត្តសោះឡើយ។ភ្លាមនោះលោកទទួលបានសារមួយពីបងប្រុស នៅអាមេរិកថា«ហេរិសេស!បងរីករាយណាស់ដែលលឺថាស្រីរីនរៀបការនៅថ្ងៃទី២៩ ព្រោះថាបង កំពុងគិតចង់ទៅស្រុកខ្មែរស្រាប់ព្រោះថ្ងៃទី៣១ជាខួបថ្ងៃស្លាប់របស់កូនស្រីបង បងចង់ធ្វើបុណ្យនៅ ស្រុកកំណើតតែម្តង!»

សារនោះធម្មតាទេប៉ុន្តែខួបស្លាប់ថ្ងៃទី៣១បានធ្វើអាយលោក វិសេសព្រឺសម្បុរគីង្គក់រវេគ្នែកក្រឡេក ក្រឡាប់ហើយសួរខ្លួនឯង៖

«ក្មួយពេជ្រស្លាប់នៅថ្ងៃទី៣១?កាលណោះនាងស្លាប់នៅយប់ដែលកំពុង រៀបការ អញ្ចឹងមានតែនាង រៀបការនៅថ្ងៃទី៣១?»

គាត់ក្រោកពីតុធ្វើការហើយដកដង្ហើមធំតែម្នាក់ឯង។រឿងហេតុដូចជារញ៉េរញ៉ៃប៉ុន្តែសរុបមកវិញគឺចម្លែក។អាចារ្យរកពេលាបាននៅថ្ងៃទី២៨ម៉េចក៏ប្រក្រតិទិននោះគូសរង្វង់ចំថ្ងៃ៣១ទៅវិញ?ហើយដាវីនក៏យល់សុបិនឆ្កួតៗមិន ខុសពីម្តាយនាងទៀត?សំឡេងភរិយាដែលនិយាយកាលពីមុនមានពិធីភ្ជាប់ពាក្យលាន់មកវិញក្នុងសោតាហាក់នៅថ្មីៗ«បងនៅចាំរឿងសក្ការប្អូនស្រីបងអត់?សក្កណាស្លាប់ក្នុងយប់រៀបការគឺពេលជប់លៀងទទួល ភ្ញៀវ.!សក្កណាស្លាប់បងថាមកពីនាងមានគ្រោះថ្នាក់ ចុះក្មួយស្រីបង ក្មួយពេជ្រកាលពី៦ខែមុនរៀបការនៅ អាមេរិកម៉េចក៏ស្លាប់ក្នុងយប់ជប់លៀងដែរ?ហើយនៅចាំអត់ ប្អូនស្រីជីដូនមួយបងឯងក៏ធ្លាប់ស្លាប់ក្នុងយប់រៀបការដែរ!សរុបមក ខ្ញុំយល់ស្រីៗក្នុងផ្ទះនេះ គឺមានបញ្ហាក្នុងយប់រៀបការទាំងអស់ ម៉េចក៏ជួនគ្នាម៉េះ?»

ដកអារម្មណ៍ចេញពីសម្តីមិន គួរអោយចង់ស្តាប់របស់ភរិយាដែលនៅតែតាមមកអន្ទោលក្នុងអារម្មណ៍ លោកវិសេសចាំបាច់ត្រូវតែត្រឡប់ទៅកាន់កុំព្យូទ័រហើយឆែកមើលឯកសារចាស់ៗស្តីពីមរណភាព របស់ប្អូនស្រីបង្កើត ប្អូនស្រីជីដូនមួយនិងក្មួយស្រីនៅ អាមេរិកកាលពី៦ខែមុន។

រកឃើញកាលណាគាត់ដាក់បង្គុយប៉ុកទៅលើកៅអីព្រោះថាអ្នកទាំងនោះសុទ្ធតែស្លាប់ក្នុងយប់រៀប ការ ហើយពិធីរៀបការទាំងបីនោះគឺនៅចំថ្ងៃទី៣១ខែមករាទាំងអស់។

«ស្អីគេអ៊ីចេះ?ថ្ងៃទី៣១ទាំងអស់?»

លោកវិសេសក្រោកចាកចោលការិយាល័យហើយបញ្ជាអោយសូហ្វ័រចេញឡានរត់រឹងមកផ្ទះ។នៅ តាមផ្លូវគាត់ពោលសួរទៅកាន់អ្នកបើកបរជំនិត៖

«ពូឆែម!ពូនៅចាំកាលសក្កណាប្អូនខ្ញុំស្លាប់ទេ?»

«តាំងពី២០០២ឯណោះលោកក្មួយ!»

«កាលហ្នឹងនាងកើតចីក្នុងយប់រៀបការហ្នឹង?»

«អត់ដឹងច្បាស់ដែរក្មួយ!ពេលជប់លៀងភ្ញៀវ អ្នកនាងតូចចូលទៅជាមួយផ្ទួងប្រហែលជាទៅប្តូរឈុត តែមិន ឃើញចេញមកវិញ!យូរពេកទៅ  អ្នកស្រីធំម្តាយលោកក្មួយក៏អ្នកស្រីម៉ាក់អ្នកនាងដាវីនចូល

ទៅតាមស្រាប់តែចេញមកវិញគាត់រែកស្លន់ស្លោថាឃើញអ្នកនាងសក្កណាលង់ទឹកស្លាប់ក្នុងអាងទឹកក្រោយផ្ទះ?»

លោកមេធាវីវិសេសនិយាយរអ៊ូតិចៗ៖

«ពូឆៃម!កាលពី៦ខែមុនបងវិសាលនៅអាមេរិកកូនគាត់ក៏ស្លាប់ក្នុងថ្ងៃរៀបការដែរ!ក្មួយខ្ញុំស្រីពេជ្រស្លាប់នៅយប់ជប់លៀងនោះទៀត ធ្វើអោយម៉ាក់ដាវីនគេមិនសប្បាយចិត្តសោះ គេគិតថាស្រីៗក្នុងផ្ទះនេះ ហេតុអ្វីចេះតែស្លាប់បន្តបន្ទាប់គ្នាក្នុងពេលរៀបការដូចគ្នា!»

«ចុះអ្នកនាងពេជ្រនៅអាមេរិកស្លាប់ដោយរបៀបណាមិនសមថាលង់ទឹកដូចគ្នាដែរទេដឹងលោកក្មួយ?»លោកវិសេសហាក់ភ្ញាក់ព្រើតនិមិត្តតែលឺពាក្យដាស់តឿន នេះ។គាត់លើកទូរស័ព្ទចុចបណ្ដើរនិយាយតបអ្នកបើកបរជំនិតបណ្ដើរផង៖

«ត្រូវហើយ!គួរសួរបងសាលសិន!»

សូហ្វ៊ីរចំណាស់នៅស្ងៀមចាំស្ដាប់ការសន្ទនារវាងចៅហ្វាយដែលកំពុងពេញដោយក្ដីពិភាល់។ចំណែកបុរសចំណាស់នេះក៏ទំនងជាដឹងរឿងច្រើនដែរទាក់ទងនឹងមរណភាពស្រីៗក្នុងត្រកូលនេះ។យូរៗម្ដងគាត់លើកដៃជ្រោងសក់ព្រោះស្មុគស្មាញមិន ដឹងថាអ្វីដែលគាត់បានគិតនិងកំពុងគិតត្រឹមត្រូវរឺក៏អត់ហើយតើគាត់គួរនិយាយជាមួយលោកក្មួយជាមេធាវីនេះតាមត្រង់រឺយ៉ាងណាទេ។

ពេលគាត់កំពុងខ្វល់ខ្វាយ សំឡេងបុរសជាមេគ្រួសារនិយាយ មកប្រាប់គាត់៖

«ពូអ្ហ៊ាក្មួយពេជ្រក៏លង់ទឹកស្លាប់ដូចគ្នា តែនាងច្រមុជក្បាលសម្លាប់ខ្លួនក្នុងអាងបន្ទប់ទឹក!»

សូហ្វ៊ីរឡានវ័យចំណាស់បង្ហាញទឹកមុខស្លេកស្លាំង ដៃទាំងគូរលើចង្កូតចាប់ផ្ដើមញ័រចំប្រប់។

ភាគទី២

មេធាវីនិយាយបន្ត៖

«តាមប្រសាសន៍បងសាលគឺក្មេងៗវាស្រលាញ់គ្នាបានគាត់រៀបការអោយ!ទំនាក់ទំនងក្មួយពេជ្រនិងខាងប្រុសក៏ល្អ មិនបានចាប់បង្ខំអីទេ!ចុះហេតុ អីក៏ក្មួយពេជ្រគិតខ្លីអីដល់ម្លឹង?!ដាច់ចិត្តទៅសម្លាប់ខ្លួនឯងធំធាត់នៅប្រទេសជឿនលឿនផង វាដូចជាមិន សមសោះពូ»

សូហ្វ៊ីរដកដង្ហើម ធំមិនទាន់ហ៊ានតបថាយ៉ាងណាផង។ស្រាប់តែលោកមេធាវីនិយាយបន្ថែម៖

«ពូ!ដែលខ្ញុំនឹកឆ្ងល់គឺ ក្មួយពេជ្រនិងសក្កណាសុទ្ធតែរៀបការថ្ងៃទី៣១ដូចគ្នា ហើយ....»

គាត់មិនទាន់និយាយចប់ ស្រាប់តែពូ សូហ្វ័រសួរមកវិញ៖

«ចុះអ្នកនាងវិហ្សាប្អូនជីដូនមួយលោកក្មួយកាលពីបួន ៥ឆ្នាំមុនក៏ស្លាប់ដែរនោះ ចំយប់រៀបការហើយ ចំថ្ងៃទី៣១ដូចគ្នាដែរអត់?»

លោកមេធាវីដែលបានផែកឯកសារចាស់ៗអស់ហើយនោះងក់ក្បាលយឺតៗ៖

«ដូចគ្នាពូ!ថ្ងៃទី៣១!»

អ្នកទាំងពីរនៅស្ងៀមទាំងតឹងចិត្តចំពោះចំណោទបញ្ហាដ៏អាថ៌កំបាំងចំពោះមុខ បណ្ដោយអោយរថយន្តបោលសម្រុកទៅមុខលឿនដូច ហោះ។ភ្លាមនោះលោកមេធាវីវិសេសនិយាយបន្ថែម៖

«ពូ!ភរិយាខ្ញុំគេយល់សប្តិមិនល្អទេយប់មិញ!កូនវីនក៏យល់សប្តិផ្តេសផ្តាសឃើញថ្ងៃទី៣១ហ្នឹងដែរ! សំខាន់ម្សិលមិញតាអាច្រប្រាប់យើងថាពេលាស្រីវីនបានចំថ្ងៃទី២៩តែគាត់គូសទៅលើលេខ៣១ទៅវិញ?ត្រង់ ហ្នឹងហើយដែលធ្វើអោយម៉ាក់វាមិនអស់ចិត្ត គេខ្លាចណ៎ាពូ គេខ្លាចកូនស្រីគេមានរឿងដូចសក្ក ណានិងក្មួយពេជ្រ។សំខាន់ តាអាចារ្យគាត់និយាយថាពេលាបា២៩គាត់គូសរង្វង់ជុំវិញលេខ ២៩ពីណាំក៏ឃើញ ស្រាប់តែ

យប់គេឡើងរង្វង់នោះនៅជុំវិញលេខ៣១ទៅវិញ!យើងមានរឿងរហូតទាក់ទងនឹងរៀជបការថ្ងៃទី៣១ម្តងនេះខ្ញុំច្បាស់ជាមិនអោយស្រីវីនយកថ្ងៃហ្នឹងទេពូ!»

បុរសដែលមិនសូវហ៊ាននិយាយស្តីបែរជាងាកក្រោយវឹងហើយអោយយោបល់៖

«លោកក្មួយ យើងផែកកាម៉េរ៉ាយើងទៅ!ចាំមើលអាចារ្យនិយាយខុសរឺមួយក៏មានរឿងអីផ្សេង!?»

លោកមេធាវីបើកភ្នែកគ្រលួងហើយសញ្ជឹងគិតក្នុងចិត្ត៖

«សម្តីពូផែមមានន័យថាគាត់ក៏មិនជឿថា តាអាចារ្យច្រឡំដែរ?»

ពេលគាត់មិនឃើញថៅហ្វាយចេញស្តី ពូផែមឆ្លៀតនិយាយបន្ត៖

«មិនដែលមានពីណាច្រឡំអីដល់ថ្នាក់មនុស្សពេញផ្ទះគេលីពេលាគ្រប់គ្នាដល់មកគូស គូសថ្ងៃផ្សេងទេលោកក្មួយ!»

លោកមេធាវីងក់ក្បាលៗផ្ងក់ៗទទួលយកយោបល់នោះ។មកដល់ផ្ទះកាលណា មនុស្សក្នុងផ្ទះនាំគ្នានឹកឆ្ងល់ត្បិតឃើញលោកមេធាវីនិងសូហ្វ័រជំនិតរលះរលាំងធ្វើការងារអ្វីមួយ ហើយលោកវិសេសបដិសេធមិនព្រមហូបបាយដែលមានភរិយានៅរង់ចាំនិងកូនស្រីរួចស្រេចដូចសព្វដង។

ពេលកូនប្រពន្ធដឹងថាគាត់និងសូហ្វ៍កំពុងរួមដៃគ្នាឆែកកាមេរ៉ាសុវត្ថិភាពក្នុងបន្ទប់ទទួល ភ្ញៀវអ្នកស្រីចន្ថាដែលមានសុខភាពផ្លូវចិត្តមិនសូវល្អស្រាប់សួរឡើងទាំងបារម្ភ៖

«បងចង់ធ្វើអីហ្នឹង?បងសង្ស័យមានចោរចូល ផ្ទះយើងមែនទេ?»

«អត់ទេ!បងចង់ដឹងថា ម្សិលមិញតាអាចារ្យគូសថ្ងៃ២៩រឺថ្ងៃទី៣១?»

ភរិយានិងកូនមើលមុខគ្នា ព្រោះស្ទើរមិន ជឿត្រចៀកថាប្តីដែលធ្លាប់តែរវល់សឹងរកពេលសម្រាកគ្មានពេលនេះបានស្ម័គ្រចិត្តឆែកកាមេរ៉ានោះ ក៏ព្រោះមិនអស់ចិត្តរឿងពេលាកូនស្រី។អ្នកស្រីចន្ថាទាញកូនស្រីទៅចង្ក្រានបាយខ្សឹបនាងថា៖

«តាមមើលប៉ាកូនក៏សង្ស័យដែរដោយសារម៉ាក់យល់សប្តិអាក្រក់ពេក!»

ដារីននិយាយតបនិងម្តាយទាំងទឹកមុខស្លេក៖

«ហើយថែមទាំងកូនយល់សប្តិអាក្រក់ទៀតណ៎ាម៉ាក់ កូនមិនចង់ជម្រាបម៉ាក់ទេ តែកូនបានជម្រាបប៉ាហើយ គឺទាកទងនឹងថ្ងៃទី៣១ហ្នឹង!ប្រហែលអញ្ចឹងហើយបានជាប៉ាចង់ដឹងច្បាស់ថាអាចារ្យនិយាយច្រឡំរឺអី»

ពូឆែមដែលចេញពីហូបទឹកនិយាយតបទៅកាន់អ្នកស្រីវិញ៖

«អ្នកស្រី!មិនមែនត្រឹមតែប៉ុណ្ណឹងទេ គឺលោកប្រុសទើបតែដឹងថាទាំងអ្នកនាងសក្កណា អ្នកនាងវីហ្សាអ្នកនាងពេជ្រដែលស្លាប់នៅយប់រៀបការគឺសុទ្ធតែចំថ្ងៃទី៣១ !»

អ្នកស្រីចន្ថាបើកភ្នែកធំៗស្ទើរគាំងបេះដូង ដៃជើងចាប់ផ្តើមញ័រកុំតែបានកូនស្រីរត់មកត្រកងទាន់។

ពូឆែមខំនិយាយសម្រួល ចិត្តវិញភ្លាមពេលឃើញដូច្នោះ៖

«តែលោកប្រុសថាដាច់ខាតមិនអោយអ្នកនាងតូចរីនរៀបការថ្ងៃហ្នឹងទេ!ហើយឆែកកាមេរ៉ានេះគឺអោយច្បាស់ថា តាអាចារ្យបានពេលាថ្ងៃ២៩រឺ៣១!»

សម្រែករ៉ាស់លាន់ចេញពីក្រអូមមាត់បុរសមេធាវីដែលមិនធ្លាប់សូម្បីតែនិយាយលឺ ធ្វើអោយអ្នកទាំងបីក្នុងផ្ទះបាយលឺហើយកាន់តែតក់ស្លុតប្រញាប់រត់ទៅក្បែរលោកមេធាវីវិសេស។

មិត្តអ្នកអានស្មានមិនដល់ទេថា ពេលដែលលោកវិសេសនាំកូនប្រពន្ធឆែកកាមេរ៉ាទៅគឺឃើញថាលោកតាអាចារ្យបានគូសចំលេខ២៩ច្បាស់លាស់តែពេលពួកគេជាប់រវល់ជជែកហើយដាក់

ប្រក្រតិទិនទៅលើតុ សាឡុងដោយមិនបានរវល់យកចិត្តទុកដាក់ កាមេរ៉ាចាប់បានរូបស្រីម្នាក់ដែលចេញមកពីណាមិនដឹងមកលុបរង្វង់នោះចេញហើយគូសទៅលើលេខ៣១វិញ។

អ្នកស្រីចន្ថាឃើញវីដេអូនោះកាលណាដួលត្បោលសន្លប់បាត់មាត់បាត់ក ចំណែកកញ្ញាដាវីនស្រែកដោយរន្ធត់ ថា «ប៉ា!ស្រីនោះហើយដែលកូនឃើញក្នុងយល់សប្តិ!»។

នាងថាបានត្រឹមប៉ុណ្ណឹងស្រាប់តែខ្មោចស្រីក្នុងកាមេរ៉ាងើបមុខមកសម្លក់ពួកគេធ្វើអោយទាំងឪពុកទាំងកូនគាំងចលនាស្រែកលែងចេញ។ពូឆែមទន់ជើងអង្គុយប៉ុកផ្ទាល់តដ្ឋ ចំណែកដាវីនស្ទុះទៅគ្រាម្តាយនៅសល់តែលោកវិសេសដែលនៅគាំងស្ទេញមុខកាមេរ៉ា។លោកវិសេសនៅញ័រដៃទទ្រើកពីមុខកាមេរ៉ាដែលស្រីខ្មោចកំពុងសម្លក់មកគាត់ហើយរាងកាយនាងកាន់តែរីក ធំឡើងៗសឹងថាពេញមួយអេក្រង់។ក្នុងពេលដែលទទួលអារម្មណ៍ថាខ្មោចនោះនឹងចេញពីក្នុងអេក្រង់មកក្រៅច្បាស់ ណាស់ប៉ុន្តែដៃជើងលោក មេធាវីទៅជាទន់ ល្វើយរកលើកធ្វើអ្វី ក៏មិន រួចសោះព្រោះចាញ់ក្តីតក់ស្លុត។ខ្មោចគិតពីសម្លក់ហើយនិយាយលាន់ ខ្ទរគេហដ្ឋាន៖

«ជិតដល់ពេលហើយ!ថ្ងៃទី៣១នេះ កូនស្រីឯងនឹងស្លាប់!គឺសេចក្តីស្លាប់»

ថាហើយវា លមុខ មកកាន់តែកៀកនឹងលោកមេធាវីដែលកំពុងភ័យស្រែកលែងចេញ។គាប់ ជួនពេលនោះលោកសម្បត្តិជាដន្លងបើកឡានកាត់នឹកឃើញចង់ចូលមកសួរនាំពិភាក្សារឿងកន្លែងរៀបការក៏មកដល់ចុចកណ្តឹងពីខាងក្រៅលាន់ខ្ទរផ្ទះ ទើបខ្មោចស្រីរលាយរូបបាត់ពីកាមេរ៉ាវិញ។

ដោយមិនអាចលាក់បាំងបានលោកវិសេសក៏រៀបរាប់រឿងរ៉ាវហួសវិស័យនឹងជឿនោះអោយពួកគាត់ជួយគិត។លោកសម្បត្តិស្តាប់ចប់កាលណា យល់សាច់ការថាពិតមិនប្រក្រតីក៏បានស្ម័គ្រនាំគ្រួសារលោកមេធាវីជាដន្លងទៅរកអ្នកសច្ចំមួយ រូបនៅស្រុកកំណើតឯខេត្តបាត់ដំបងដែលគ្រួសារខ្លួនតែងតែគោរពប្រណិប័តន៍ទុកដូចជាគ្រូបាអាចារ្យអោយជួយកាត់សេចក្តី។

បុរសទាំងបីនិងនារីទាំងទ្វេ បានប្រមូលកាមេរ៉ា សន្លឹកប្រក្រតិទិន ទិញទៀនធូបផ្កាភ្ញី ផ្លែឈើទៅជាមួយហើយបានទៅដល់ខេត្តបាត់ដំបងនៅពេលព្រលប់ ។ពួកគេបន្តដំណើរទៅកាន់ភ្នំសំពៅរហូតដល់ពេលមេឃងងឹតស្លុបតម្រង់ទៅដល់អាស្រមអ្នកសច្ចំដែលតាំងនៅក្នុងព្រៃឆ្ងាយពីភូមិអ្នកស្រុក។

ពួកគេឈប់រថយន្តចុះដើរថ្មើរជើងកាត់តាមផ្លូវរទេះដែលព្រិលស្រអាប់ដោយផ្សែងត្រជាក់ក្រោមពន្លឺខែព្រាលៗហើយតម្រង់ទៅរកអាស្រមដោយមានពូឆែមជាអ្នកកាន់ពិលបំភ្លឺផ្លូវនាំមុខជាមួយលោកសម្បត្តិ។

«លោកបង!យើងអត់មានលេខទាក់ទងមកលោកមុន ចុះបើលោកមិននៅអាស្រម តើត្រូវធ្វើម៉េចទៅ?»លោកវិសេសពោលសួរទាំងបារម្ភព្រោះភរិយានឹងកូនស្រីមុខស្លេកសឹងថាគ្មានឈាមមួយដំណក់ទេ។

លោកសម្បត្តិដឹងថាសម្លាញ់ ខ្លួននេះបានបាក់ស្បាតចំពោះរឿងមិនគួរអោយជឿទើបសុខចិត្តតាមខ្លួនមកទាំងយប់ព្រលប់ ក៏ខំពន្យល់វិញថា៖

«មិនអីទេវិសេស!លោកមិនដែលចេញទៅណាឆ្ងាយពីអាស្រម ដែលខ្លាច នោះ គឺខ្លាចក្រែងលោកជាប់ភាវនាមិនទទួលភ្ញៀវទៅវិញ!»លោកសម្បត្តិឆ្លើយតបតិចៗហើយចេះតែរុលដើរទៅមុខក្រោមភាពស្ងាត់ជ្រងំគ្មានសូម្បីតែសូរសម្លេងសត្វល្អិត។អ្នកស្រីចន្ថាសួរវិញភ្លាម៖

«ល្បែង!ចុះបើយើងដល់ហើយ អ្នកសច្ចំបែរជារវល់ភាវនាដូចដែលល្បងថា ហើយគាត់មិនរវល់នឹងជួយយើង គិតអាម៉េចវិញទៅ?»

លោកសម្បត្តិមិនទាន់បានឆ្លើយផង សំឡេងមួយលាន់មកក្បែរសោតាមនុស្សគ្រប់គ្នា៖

«ឃើញសត្វលង់ទឹក ត្រូវតែជួយហើយ!»

នោះគឺជាសំឡេងអ្នកសច្ចំដែលលាន់មកតាំងពីអាស្រមចម្ងាយប្រមាណ៥០មពីទីនេះ។មនុស្សគ្រប់គ្នាត្រូវស្ងាត់មាត់ច្រៀបព្រោះថា ចម្លើយរបស់អ្នកសច្ចំជារកាបង្ហាញស្រេចហើយ ថាលោកជ្រាបពីដំណើរទាំងយប់ព្រលប់នេះសឹងថាលោកបានជ្រាបនូវហេតុការណ៍ដើមចមនៃខ្មោចស្រីក្នុងកាមេរ៉ា ដែរ។ពិសេសសូម្បីអព្ភូតហេតុទាក់ទងនឹងការប្តូរគំនូសរង្វង់ពីលេខ២៩មកលេខ៣១នោះផង។

«ឆ្ងាយយ៉ាងនេះហេតុអ្វីគាត់ស្តាប់លឺ យើងនិយាយ? »

ដារីនងាកសួរម្តាយតិចៗ តែម្តាយខំពន្យល់កូនស្រីវិញ៖

«អ្នកបួសមានមាត់ទិព្វត្រចៀកទិព្វអញ្ចឹងហើយកូន!តោះកុំមាត់លឺ!»

អ្នកស្រីចន្ថាផ្តល់ក្តីសង្ឃឹមទាំងស្រុងទៅលើអ្នកសច្ចំនេះព្រោះផ្លូវក្នុងគឺជាក្តីសង្ឃឹមចុងក្រោយរបស់គាត់។

ទៅដល់ភ្លាមអ្នកសច្ចំបានបិទ ភ្នែកប្រមាណជិតមួយម៉ោងទុកអោយក្រុមអ្នកដំណើរទាំងប្រាំរូបនៅអង្គុយប្រណមលើកន្ទេលក្រាលផ្ទាល់នៅនឹងដីអត់ធ្មត់រង់ចាំដំណោះស្រាយនិងការបំភ្លឺទាំងចិត្តអន្ទះសា។លំអងផ្សែងកាន់អព្ភតែត្រជាក់ក្នុងតំបន់ព្រៃក្បែរជើងភ្នំ។

ទម្រាំអ្នកសច្ចំភាវនាឈ្វេងយល់ដឹងរឿងសព្វគ្រប់ហើយបើកព្រះនេត្រឡើងដកដង្ហើមធំពោល អធិប្បាយប្រាប់ក្រុមមនុស្សដែលកំពុងរង់ចាំថា៖

«ម្នាលលោកលោកស្រីចាំស្តាប់! តាមពិតរឿងរ៉ាវលើលោកនេះមិនដែលថាមានតែផ្សែងតែអត់មានភ្លើងទេ!គ្រួសារលោកបានជាប់បណ្ដាសាគេតាំងពីបុព្វបុរសមកសងមិនចេះរួចទេបានជាអ្នកស្លាប់មានបន្តបន្ទាប់សុទ្ធជាមនុស្ស ស្រីក្នុងយប់រៀបការដូចៗគ្នា»

ពូឆែមស្តាប់លឺកាលណាយំខ្សឹកខ្សួល។

តាមពិតរឿងនេះមានហេតុភេទតាំងពីជំនាន់ជីតារបស់លោកវិសេសដែលជាអ្នកមានស្តុកស្តម្ភមួយរូប។ឪពុកពូឆែមដែលជាអ្នកបម្រើផ្ទះនេះតាំងពីជំនាន់មុនធ្លាប់ប្រាប់ថាកាលពីជិត១០០ឆ្នាំមុនគាត់ជាជីតារបស់លោកវិសេស ម្ចាស់បំណុលរកស៊ីចងការប្រាក់ ដល់ កសិករតូចតាចនានាក្នុងខេត្ត។

គាត់បានរកស៊ីចងការជាមួយគ្រួសារជាច្រើន ក្នុងចំណោមនោះក៏ហើយក៏មានគ្រួសារមួយជាស្រីមេម៉ាយក្រីក្រលំបាកតោកយ៉ាកបានជំពាក់ប្រាក់គាត់មួយចំនួនទារមិនបានមួយលើកជាពីរលើក។

ក្រោយមកគាត់បានចាត់បរិវារអោយទៅទាមទារប្រាក់ នៅចំថ្ងៃភាគីកូនបំណុលរៀបការកូនស្រី ។ ដោយសារអ្នកទារមិនបានប្រយ័ត្នសម្ដី រឿងទារបំណុលនោះនោះបានលេចលឺខ្ទរខ្ទាយដល់ភាគីខាងកូនកំលោះ។ដោយសារប្រកាន់ថាខាងស្រីមានជាប់ជំពាក់វ៉ាក់វិនរឿងបំណុលច្រើនពេក គេក៏សម្រេចផ្តាច់កូន ចំពិធីហូបចុកពេលល្ងាចនៅមុខអ្នកភូមិផងទាំងឡាយ។

កូនក្រមុំនោះហេតុតែខ្មាសញាតិព្រៀងលានដាច់ចិត្តរត់ទៅជ្រមុជទឹកបឹងសម្លាប់ខ្លួនក្នុងយប់នោះទៅ។ចំណែកម្តាយនាងនោះវិញ ហេតុតែក្តីឈឺចាប់ពន់ពេកក៏បានលើកកាំបិតកាត់ផ្តាច់បំពង់កខ្លួនឯងដែរតែមុនពេលដាច់ខ្យល់បានដាក់បណ្តាសាថាអោយព្រលឹងកូនស្រីក្លាយជាខ្មោចសាហាវពោរពេញដោយអាឃាតតាមសងគំនុំនឹងតាមរំខានសម្លាប់រាល់នារីជំនាន់ក្រោយនៃត្រកូលនេះគឺក្នុងយប់រៀបការត្រូវតែស្លាប់ដោយចៀសមិនរួច។

ថ្ងៃកើតហេតុការណ៍គួរអោយរន្ធត់នោះគឺរាត្រីទី៣១ខែមករាឆ្នាំ១៩២១គឺរំលងទៅជិត១០០ឆ្នាំហើយខ្មោចស្រីនេះនៅតែស្តាប់តាមពាក្យម្តាយនាងមិនព្រមទៅចាប់កំណើតតាមចងអាឃាតគ្រួសារនេះជារៀងរហូតមក គឺគ្មានកូនស្រីរឺចៅស្រីណាម្នាក់អាចរៀបការបានទេ។

តាំងពីពេលដែលនិយាយគ្នាក្នុងឡានពូឆែមបានសង្ស័យដល់រឿងតំណាលពីមាត់ឪពុកខ្លួនទៅហើយប៉ុន្តែជាតិជាខ្ញុំបម្រើគេ ពូឆែមមិនមានថ្លើមឯណាពាសមេឃដល់ទៅហ៊ានបើកកកូរកកាយអតីតកាលរបស់គ្រួសារម្ចាស់ខ្លួនមកនិយាយជជែកវែកញែកនោះទេ។ចំណែកមេធាវីវិសេសនិងមនុស្សជំនាន់

ក្រោយៗដែលជាអ្នករងគ្រោះដោយបណ្តាសានោះមិនដែលបានដឹងរឿងនោះពីមុនមកទេព្រោះជំនាន់មុន ជីតាលោកជាអ្នកធំមិន មិនបានយកចិត្តទុកដាក់អ្វីនឹងបណ្តាសាស្ត្រីមេម៉ាយនោះរឹតតែមិនបានប្រាប់រឿងនោះអោយលឺដល់មនុស្សជំនាន់ក្រោយឡើយ។

ពេលពូឆែមកំពុងនឹកទៅដល់សម្តីឪពុកខ្លួន លោកវិសេសបានលាន់មាត់មួយៗបន្ទាប់ពីក្តីតក់ស្លុតនឹងភ្ញាក់ផ្អើល៖

«ខ្ញុំធ្លាប់ដឹងត្រឹមថា កាលពីជំនាន់លោកយាយលោកតា!ផ្ទះយើងធ្លាប់មានគេមកខ្ចីបុលហូរហែ!មិនដែលដឹងថា មានរឿងកើតឡើងគួរអោយរន្ធត់អញ្ចឹងទេ ។រឿងចងការប្រាក់ជារឿងមានពិតមែន តែមកដល់ជំនាន់លោកពុកខ្ញុំក៏បានបញ្ចប់យើងមិនបានរកស៊ីអញ្ចឹងទៀតទេ! មិន ដឹងថាដោយសាររឿងមួយនោះទើបបញ្ចប់រឺក៏យ៉ាងណា?!»

លោកមេធាវីដកដង្ហើមធំឯកូនស្រីគិតពីឈ្ងោកមុខយំ។

ពូឆែមដែលទ្រាំលាក់អាថ៌កំបាំងលែងបានក៏ឆ្លៀតបន្ថែមថា៖

«លោកក្មួយ!ទាំងនេះសុទ្ធតែជាការពិតហើយ !ឪពុកខ្ញុំតាំងពីនៅរស់ធ្លាប់និយាយប្រាប់ផ្ទាល់!ពុក ខ្ញុំជាក្មេងដែលដើរតាមហែហមលោកតាតាំងពីជំនាន់នោះ ហេតុការណ៍នោះគាត់បានឃើញផ្ទាល់ ហើយគាត់បារម្ភរឿងហ្នឹងតាំងពីអ្នកនាងសក្កណាស្លាប់ព្រោះអ្នកនាងសក្កណាជាកូនស្រីតែមួយក្នុងផ្ទះនេះបន្ទាប់ពីបណ្តាសារបស់ស្ត្រីមេម៉ាយនោះ!ហើយពេលលោកប្រុសលើកឡើងកាលពីព្រឹកខ្ញុំកាន់តែនឹកសង្ស័យទៅ ហើយ គ្រាន់តែមិនហ៊ាននិយាយ តែពេលនេះខ្ញុំសូមអះអាងថាអ្វីដែលអ្នកសច្ចំសង្រួមស្មឹងស្មាធិ៍ឃើញដូចគ្នាបេះបិទនឹងអ្វីដែលខ្ញុំបានលឺពុកកាលនៅរស់តំណាលប្រាប់»

លុះដល់លឺសេចក្តីចប់សព្វគ្រប់ពេលណាអ្នកស្រីចន្ថាយល់អស់សេចក្តី អស់ពីភ័យស្លុតស្លុង ក៏លើកដៃប្រណមថា៖

«សុំអោយអ្នកសច្ចំ អោយជួយរកវិធីដោះស្រាយជួយខ្ញុំផងត្បិតអីខ្ញុំអភព្វណាស់ទៅ ហើយ មានកូនស្រីតែមួយគត់សឹងថាមិន អាចរស់ បានទេប្រសិនបើបណ្តាសានោះពិតជាព្យាបាទដល់អាយុជីវិតកូនស្រីនាងខ្ញុំក្នុងថ្ងៃមង្គលការមែននោះ!»

អ្នកសច្ចំបានសង្រួមស្មឹងស្មាធិ៍បន្តអស់ពេលប្រមាណ២០នាទីទៀតទើបភ្ញាក់មកវិញដោយពោលប្រាប់ថា៖

«អ្នកចន្ទានិងលោកប្រុសត្រូវធ្វើរឿងមួយអោយបានប្រសិនបើចង់រក្សាជីវិតនិងសុភមង្គលកូនស្រីពិសេសគឺធ្វើអោយស្រីៗជំនាន់ក្រោយក្នុងគ្រួសារនេះបានសេចក្តីសុខគេចផុតពីគំនុំអាឃាតនោះគឺអ្នកស្រីចន្ទាត្រូវព្រមធ្វើពិធីទទួលខ្មោចស្រីនោះជាកូន សន្យារកប្តីម្នាក់អោយគេ ហើយអោយគេបានរៀបការចប់ចុងចប់ដើម ដូចអ្នកផងទាំងពួងទើបអោយខ្មោចនោះព្រមរសាយកំហឹងលះបង់ក្តីអាឃាតទៅចាប់ជាតិជាថ្មី ជាមនុស្សម្នាដូចគេឯង!បើពុំដូច ច្នោះទេខ្មោចក្រមុំនៅតែតាមចងពៀរបន្តជំនាន់ក្នុងគ្រួសារនេះ!»

និយាយរួចគាត់ងាកមកបញ្ជាក់ដាក់អ្នកស្រីចន្ទា៖

«តើនាងសុខចិត្តបណ្តោះកម្មពៀរគ្រួសារប្តីនាងអោយចប់តែត្រឹមនេះដែរទេ?ព្រមទទួលយកខ្មោចស្រីនោះជាកូនម្នាក់ទៀតដែររឺទេ?»។

អ្នកស្រីដែលកំពុងតែទន់ចំហដោយសារហេតុការណ៍មិនដែលជឿក្នុងមួយជីវិតកើតឡើងហួសវិស័យនិងរកវិធីដោះស្រាយ លុះមកលឺករណីទទួលយកខ្មោច ស្រីនោះមកធ្វើជាកូនទៀតគាត់ក៏កាន់តែមានសតិអារម្មណ៍ភិតភ័យលើសដើម។ខ្មោច ស្រីនោះកាចសាហាវហើយថែមទាំងមានរូបរាងគួរអោយខ្លាចយ៉ាងនេះ តើអោយស្មគ្រ័ទទួលមកធ្វើជាកូនម្តេចនឹងកើត?

អ្នកស្រីចន្ទាងាកទៅសម្លឹងមុខស្វាមីរង់ចាំជំនួយតែទាំងប្តីទាំងប្រពន្ធនិយាយមិនចេញព្រោះទ័លតម្រិះ។ឃើញដូច្នោះលោកសម្បត្តិជួយនិយាយ៖

«»ចន្ទា!វិសេស!ក្មេងស្រីនោះស្លាប់បិទ ភ្នែកមិន ជិតទើបមិនអាចទៅរកកន្លែងកើត ឃើញ!គួរតែជួយយកអាសារំងាប់ពីគំនុំទៅ!មានអ្នកសច្ចំជួយហើយគ្មានអ្វីត្រូវគិតទៀតទេ!

ដោយមានការគាំទ្រពីដន្លងផងគ្រួសារលោកមេធាវីនិងលោកស្រីយល់ថាចំពោះមុខគ្មានមធ្យោបាយណាល្អជាងនេះឡើយ។គិតរួចហើយស្វាមីក៏មិចភ្នែកដាក់ភរិយា បន្ទាប់មកអ្នកស្រីចន្ទាក៏កាត់ចិត្តឆ្លើយតបនឹងអ្នកសច្ចំវិញ៖

«នាងខ្ញុំសុខចិត្ត!នាងខ្ញុំសុខចិត្តទទួលយកការណ៍នេះ អោយតែអាចដោះចេញអោយអាសាបង់នូវបណ្តាសាដ៏សែនអាក្រក់នោះចេញពីវង់ ត្រកូលគ្រួសារនេះ ចាប់ពីពេលនេះទៅ»

អ្នកសច្ចំងក់ក្បាលផ្ងក់ៗកាលបើឃើញថាអ្នកស្រីនេះសុខចិត្តធ្វើពិធីលាងកម្មពៀរជីតាខាងប្តីខ្លួនដែលជំពាក់លើគ្រួសារកសិកររមេម៉ាយ។លោកបានបញ្ជាថា៖

«បើអញ្ចឹង!ចូរនាងលើកដៃឡើងប្រណមហើយនិយាយប្រាប់ម្ចាស់ទឹកម្ចាស់ដី និយាយបួងសួងដោយសុទ្ធចិត្តថាអំណើះតទៅ ប្រសិនបើខ្មោចស្រីសុខចិត្តទៅចាប់ជាតិលែងរវល់នឹងគំនុំអតីតចាស់ នាងក៏សុខចិត្តទទួលគេជាកូនស្រីទី២ហើយសន្យារកប្ដីសីរៀបការបានចប់ចុងចប់ដើមមិនអោយកម្សត់ព្រាត់ប្រាសផ្កា ស្លាទៀតដាច់ខាត!»

អ្នកស្រីនិយាយតាមអ្នកសច្ចំទាំងអស់ឥតបាត់មួយឃ្លាមួយពាក្យណាឡើយ។ខ្យល់ក៏បក់មករវ៉ូៗរំជួយអស់ស្លឹកឈើចាស់ថ្មីរុះរោយរពុយហើរមកប៉ះសាច់អ្នកដំណើរទាំងប្រាំអោយព្រឺព្រួចកណ្ដាលស្ងៃរាត្រី។

អ្នកសច្ចំចាប់ផ្ដើមចាត់អោយពូឆែមនិងលោកសម្បត្តិរៀបចំអុចទៀនធូបផ្កាភ្ញី ផ្លែឈើ នានាពិធីដោយមធ្យ័តបន្ទាប់មកគាត់ចាប់ផ្ដើមសូត្រគាថាជាច្រើនចប់ ប្រណមទៅរកទិសទាំង៨ហៅអស់អ្នករក្សាទឹកដីមកតាមជួយជំឡើងបារមីរួចទើបសូត្រលឺៗថា៖

«នាងខ្មោចកម្សត់គ្មានគោលដៅ!ផ្លូវនៅនឹងមុខនេះជាពិតប្រកបដោយបុណ្យកុសល ។វីប្ដីប្រពន្ធលោកវិសេសសាងតែអំពើជាកុសលក្នុងជីវិតរបស់គាត់ ក៏ល្មមអោយនាងពេញចិត្តព្រមបញ្ចប់គំនុំពីអតីត ហើយត្រឡប់មកសុំរស់នៅចាំកូនស្រីទីពីររបស់គ្រួសារនេះរកគោលដៅពិតប្រាកដសម្រាប់ខ្លួនឯងឡើងវិញទៅ!»

គាត់សូត្រដដែលៗនេះរហូតដល់គម្រប់៧ចប់ទើបឈប់ហើយអនុញ្ញាតអោយក្រុមអ្នកដំណើរសម្រាកលើកន្ទេលនោះរង់ចាំភ្លឺច្បាស់នឹងអាលទទួលយកទឹកមន្តវិលត្រឡប់ទៅផ្ទះវិញ។

រាត្រីនោះ ភរិយាលោកមេធាវីសម្រាកនៅអាស្រមអ្នកសច្ចំក៏សុបិនឃើញខ្មោចស្រីនោះស្លៀកពាក់ស្អាតបាតហើយញញឹមញញែមយួរបង្វេចចូលមកនៅលើផ្ទះរបស់ពួកគាត់នៅភ្នំពេញ។ពេលឃើញគាត់កាលណាវាស្រែកហៅថា«ម៉ែ»ហើយប្រាប់ថា«ម៉ែអើយពេលអ្នកបងវីនរៀបការម៉ែកុំភ្លេចពាក់អាវពណ៌ក្រហមអោយខ្ញុំ។»

អ្នកស្រីលឺដូច្នេះសួរថាវិញភ្លាមថា«ចុះកូនឯងអោយបងរៀបការថ្ងៃណាដែរ?»«ម៉ែទៅមើលលើកន្លែងតាអាចារ្យគួរនោះហើយធ្វើតាមហ្នឹងទៅ»ថាហើយខ្មោច ស្រីនោះរលាយរូបបាត់ទៅ។

ភ្លឺឡើងអ្នកស្រីតំណាលប្រាប់អ្នកសច្ចំ គាត់ក៏អោយទឹកមួយកូនក្អមប្រស់លើប្រក្រតិទិននោះ រួចផ្ដាប់ចោលសូត្រគាថា។បន្តិចក្រោយមកពេលលើកមកវិញគំនូសនោះមិនមែននៅចំថ្ងៃទី៣១ទៀតទេគឺបានពេលាថ្ងៃទី២៩ដូចពាក្យតាអាចារ្យពីដំបូង។

អ្នកសច្ចំប្រគល់អោយគ្រួសារទាំងពីរនូវផ្ទាំងប្រក្រតិទិននោះវិញ ហើយបញ្ជាថាខាងស្រីត្រូវស្រូតទៅភ្នំពេញធ្វើពិធីប្រស ព្រំក្នុងផ្ទះបោសសំអាតកម្មពៀរភាពងងឹតអពមង្គលផងទាំងឡាយ ទទួលសមាជិកថ្មីក្នុងគ្រួសារនេះ។

គ្រួសារមេធាវីបានធ្វើតាមពាក្យបណ្តាំអ្នកសច្ចំឥតមានភ្លេចមួយប្រការណាឡើយ។បន្ថែមពីលើនោះគាត់បានធ្វើបុណ្យដាក់ទានដល់ទុរគតជនហើយបានអោយពូឆែមនាំទៅកាន់ភូមិគ្រួសារកសិករស្រីមេម៉ាយនោះសាកសួរព័ត៌មានស្វែងរកសាច់សារលោហិតដែលនៅរស់សល់នាំគ្នាធ្វើបុណ្យឧទ្ទិសកុសលបញ្ជូនព្រលឹងស្រ្តីនោះទៅកាន់សុគតិភពនឹងសុំអហោសិកម្មរវាងគ្នានឹងគ្នាត្រឹមពេលនេះ។

ប្រកបដោយស្មារតីជ្រះថ្លា លោកវិសេសបានរៀបចំមង្គលការរបស់កូនស្រីជាមួយជន្លងខ្លួនដោយរីករាយចាកផុតទុក្ខព្រួយនានា។ជិតដល់ថ្ងៃកូនស្រីរៀបការ លោកស្រីចន្ថាចាប់មានផ្ទៃពោះ ធ្វើអោយគ្រប់គ្នាជឿថា ច្បាស់ជានាងនោះមកចាប់កំណើតតាមការធ្វើពិធីព្រមទទួលយកដោយស្មោះរបស់គ្រួសារលោកមេធាវី។

អ្នកស្រីចន្ថានិងលោកវិសេសរីករាយពន់ពេកដោយសារថានេះជាសំណាងល្អដោយមិននឹកស្មានថាកាលពីវ័យក្មេងចង់បានកូន ច្រើនតែមិនបានសោះ ពេទ្យថាអ្នកស្រីគ្មានលទ្ធភាពមានកូនទី២ទេស្រាប់តែពេលនេះកូនម្នាក់ជិតរៀបការចេញ បែរជាម្តាយអាចពរពោះជាថ្មីទៅវិញ។

អ្នកស្រីចន្ថាដែលនៅតែទន្ទេញចាំពាក្យបណ្តាំរបស់ស្រីខ្មោចនោះក្នុងពេលពន្យល់សប្តគាត់ គាត់ក៏បានអោយគេច្នៃកាត់អាវសូត្រពណ៌ក្រហមស្រស់មួយសម្រាប់ពាក់ក្នុងពិធីមង្គលការដាវីន។

ចាប់ពីពេលនោះមក ដាវីបានរួមរស់ជាមួយស្វាមីដោយក្តីសុខដុមរមនាតាមចរិតគ្រួសារទាំងពីរដែលសុទ្ធ សឹងមានជីវិតរស់នៅបែបថ្លៃថ្នូរមិនបៀតបៀនធ្វើបាបអ្នកណា។

*មតិអ្នកនិពន្ធ៖*

ករណីផ្លូវងងឹតបានដើរប្រឆាំងគ្នាទៅនឹងវិទ្យាសាស្រ្តដ៏ទំនើបនាសម័យកាលឌីជីថលប៉ុន្តែសូម្បីប្រទេសជឿនលឿនជាច្រើនក្នុងពិភពលោកក៏នៅតែបន្តជជែកគ្នាមិន ដាច់ស្រេចពីរឿងគ្រូអូមអាមខ្មោចព្រាយបិសាចនេះដែរ។

នៅក្នុងប្រទេសកម្ពុជាយើងដែលសម្បូរទៅដោយពុទ្ធបរិស័ទជឿលើអំពើបាបបុណ្យសាងល្អបានល្អនោះ ចាស់ទុំដែលអ្នកនិពន្ធបានជួបបាននិយាយថា នៅតំបន់មួយចំនួនគេនៅតែមានជំនឿថាប្រសិនបើខ្មោចតែហោងស្លាប់ក្នុងពេលគេកំពុងធ្វើពិធីអ្វីមួយតាមបែបប្រពៃណី ហើយពិធីនោះជាពិធីដ៏សំខាន់ផង វិញ្ញាណរបស់គេមិនអាចទៅណាបានមានតែនៅវិលវល់ស្តាយស្រណោះថាមិនបាន

បំពេញពិធីចប់ ចុងចប់ដើម ហើយ បន្ទាប់មកក៏កើតជាការចងអាឃាតទៅលើបុគ្គលទាំងឡាយដែលពាក់ព័ន្ធ។ចំណែកពាក្យបណ្ដាសាដោយស្ត្រីជាម្ដាយខ្មោច ស្រីនោះហាក់ស្របគ្នាទៅនឹងពាក្យចាស់ៗដែលតែងលើកឡើងថាអ្នកដែលរងអយុត្តិធម៌រីការឈឺចាប់ហួសហេតុមុនពេលស្លាប់គេអាចយកជីវិតចុងក្រោយរីលោហិតរបស់គេផ្ទាល់នោះជាកម្លាំង ងងឹតដាក់បណ្ដាសាណាមួយហើយបណ្ដាសានោះនឹងក្លាយជាការពិតមិន ងាយដោះរួចឡើយ លើកលែងតែយើងអាចរកឃើញមូលហេតុពិតរបស់វា។

រឿងរ៉ាវក្នុងគ្រួសាររបស់លោកមេធាវីបានកើតឡើងតាំងពីជំនាន់ជីតាគាត់ដូច្នេះ អ្នកជំនាន់ក្រោយមិនអាចស្វែងយល់បានទេប្រសិនបើគ្មានការពន្យល់ពីអ្នកដែលមានទំនាក់ទំនងនឹងផ្លូវងងឹតពោលគឺអ្នកដែលអាចជួបជជែករីនិយាយហេតុផលជាមួយវិញ្ញាណខ្មោចព្រាយបិសាចបាន។

ចំណែកអ្នកនិពន្ធគ្រាន់តែចង់អោយមនុស្សគ្រប់គ្នាក្នុងសង្គមចាប់ផ្ដើមអោយតម្លៃលើអំពើល្អ យោគយល់ និងចេះស្គាល់បាបបុណ្យគុណទោសជៀសអោយបាននូវការបៀតបៀនគ្នា ពិសេសការរុញមនុស្សដូចគ្នាអោយទ័ល ច្រករហូតដល់មិនអាចរស់រានមានជីវិតបាន។
ចុះអ្នកយល់យ៉ាងណាដែរចំពោះការតំណាលក្នុងរឿងនេះ? **ចប់**